ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ២២០

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

**សាលដីកា**

លេខ ៣៩៩ "ជ"

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលបានប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ **២២០** ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ មានដូចខាងក្រោម ៖

**-ជនជាប់ចោទមាន៖**

១-ឈ្មោះ [redacted] សារុំ ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើចំការ កើតនៅភូមិជីមាន់ ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តឧត្តមានជ័យ ប្រពន្ធឈ្មោះ[redacted] មានកូន ០៤នាក់ ឪពុកឈ្មោះ[redacted] (ស្លាប់) ម្តាយឈ្មោះ[redacted]



Scanned with CamScanner

(ស្លាប់) កម្រិតវប្បធម៌ថ្នាក់ទី៤ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន" ។ **(ក្នុងឃុំ) (អ្នកប្តឹងឧទ្ធរណ៍)**

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **១២២២ គ-ព្រ** ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ។

២-ឈ្មោះ [redacted]**សារ៉ាត ហៅ ហើម ឬ រម្យ** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិក្ងួរ ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្ប[redacted] ពញាក្រែក ខេត្តត្បូងឃ្មុំ ពោះម៉ាយ មានកូន ០១នាក់ ឪពុក ឈ្មោ[redacted] (រស់) ម្តាយឈ្មោះ[redacted] (រស់) កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន" ។ **(ក្នុងឃុំ) (អ្នកប្តឹងឧទ្ធរណ៍)**

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **១២២១ គ-ព្រ** ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ។

ជាប់ចោទពីបទ **រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យសោហ៊ី ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២០ ។

+ដោយមានលោក[redacted]ន្ទុនធឿន អគ្គលេខ[redacted]ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## **អំពីអង្គហេតុ**

កាលពីថ្ងៃ២៨ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៣ និង ៣០នាទី នៅចំណុចមុខអនុវិទ្យាល័យសោហ៊ី ស្ថិតនៅក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន សហការនឹងកម្លាំងក្រុមអន្តរាគមន៍ប្រឆាំងបទល្មើស បានធ្វើការបង្ក្រាបករណីគ្រឿងញៀន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted]សារុំ ភេទប្រុស អាយុ ៥៩ឆ្នាំ បានទាក់ទងទិញគ្រឿងញៀនប្រភេទម៉ាទឹកកកចំនួន ០៥គីឡូក្រាម ពីជនមិនស្គាល់ឈ្មោះ ។ បន្ទាប់មកឈ្មោះ[redacted] សារុំ និងបក្ខពួកឈ្មោះ [redacted]ហួយ ភេទប្រុស អាយុ៤៧ឆ្នាំ ឈ្មោះ[redacted]សារ៉ាត ភេទប្រុស អាយុ ៣៥ឆ្នាំ បាននាំគ្នាជិះម៉ូតូយកថ្នាំញៀនទៅលក់ឱ្យគេ រួចក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន ដកហូតបានគ្រឿងញៀន និងបាននាំខ្លួនមកសាកសួរតែម្តង ។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ "ក" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេច៖

**១-ផ្តន្ទាទោសដាក់ពន្ធនាគារលើ៖**

១-១-ឈ្មោះ[redacted]សារុំ ភេទប្រុស អាយុ ៥៩ឆ្នាំ (មានសាវតារជាតិដូចខាងលើ)

១-២-ឈ្មោះ [redacted]សារ៉ាត ភេទប្រុស អាយុ ៣៥ឆ្នាំ (មានសាវតារជាតិដូចខាងលើ)



Scanned with CamScanner

ក្នុងម្នាក់ៗកំណត់រយៈពេល ២០ឆ្នាំ(ម្ភៃឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួនបណ្ដោះអាសន្ន និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៨០.០០០.០០០រៀល(ប៉ែតសិបលានរៀល) បង់ចូលជាថវិការដ្ឋ ពីបទ "រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យសោហ៊ី ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២០ ។

២-វត្ថុតាង(ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៦៤៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង) រួមមាន៖

២-១-ថ្នាំញៀនក្រាមម្សៅប្រភេទ មេតំហ្វេតាមីន (ហៅក្រាម៉ាទឹកកក ឬអាយ) ទម្ងន់ ៤៨ ៧០.៣៧ក្រាម ត្រូវរឹបអូសយកទៅបំផ្លាញចោល ។

២-២-ទូរស័ព្ទដៃ ០១គ្រឿង ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋ ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]សារុំ និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ។

-ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ តាមកាលកំណត់នៃច្បាប់។

-បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] បានប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ "ក" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់សេចក្ដីសម្រេចទាំងមូល ។

-បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]សារ៉ាត បានប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ "ក" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់សេចក្ដីសម្រេចទាំងមូល ។

**-បានឃើញ** ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ **២៣១ ព្រទ.ឧបប/២២** ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង។

-បានឃើញ របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សារុំ បានឆ្លើយថា ៖ បានជាខ្លួនប្តឹងមកឧទ្ធរណ៍ព្រោះខ្លួនមិនសុខចិត្តនឹងការសម្រេចរបស់សាលាដំបូងខេត្តបាត់ដំបង ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនមកខេត្តបាត់ដំបងនឹងគឺខ្លួនមកជួបមិត្តភក្តិដើម្បីមកនិយាយគ្នាពីរឿងទិញដី។ ចំពោះថ្នាំញៀននឹងគឺខ្លួនមិនបានទិញយកមកជួញដូរនោះទេ ។ ខ្លួនទទួលស្គាល់ថាឈ្មោះ ខូយ បានផ្ញើកវ៉ាន់ឱ្យខ្លួនយកទៅឱ្យគេនៅក្បែរស្ពាននោះមែន ប៉ុន្តែខ្លួនមិនបានដឹងថានៅក្នុងនឹងជាថ្នាំញៀននោះទេ ។ ចំពោះឈ្មោះ [redacted] សារ៉ាត គាត់មិនបានដឹងរឿងអ្វីទាំងអស់គឺខ្លួនហៅគាត់មកដើម្បីមានគ្នាមកជាមួយ ។ សំណូមពរសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត បានឆ្លើយថា៖ បានជាខ្លួនប្តឹងមកឧទ្ធរណ៍ព្រោះខ្លួនមិនសុខចិត្តនឹងការសម្រេចរបស់សាលាដំបូងខេត្តបាត់ដំបង ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] សារុំ បានឱ្យខ្លួនជូនមកខេត្តបាត់ដំបង ដើម្បីមកជួបមិត្តរបស់គាត់ ។ នៅពេលដែលខ្លួន និងឈ្មោះ [redacted] សារុំ ជិះម៉ូតូចេញមកពីម៉ុក្បាលខ្មោច បានប្រហែល៥០ម៉ែត្រស្រាប់តែឈ្មោះ [redacted] សារុំ បានឱ្យខ្លួនចុះពីលើម៉ូតូនៅចាំគាត់ ដោយគាត់ប្រាប់ថា ទៅជួបមិត្តរបស់គាត់ ហើយ១៥នាទីក្រោយមកគាត់ក៏មកយកខ្លួនវិញដោយខ្លួនមិនបានឃើញអ្វីប្លែកនៅនឹងម៉ូតូឡើយ ។ បន្ទាប់មកទៀតឈ្មោះ [redacted] សារុំ បានឌុបខ្លួនមកក្រុងបាត់ដំបង ដើម្បីជួបមិត្តរបស់គាត់ ពេលនោះជិះតាមផ្លូវឈ្មោះ [redacted] សារុំ ឱ្យខ្លួនចុះពីលើម៉ូតូម្តងទៀតដោយគាត់ប្រាប់ថា គាត់ទៅជួបមិត្តរបស់គាត់ បន្ទាប់មកឈ្មោះ [redacted] សារុំ បានជិះម៉ូតូចេញពីខ្លួនប្រហែល ៥០ម៉ែត្រ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] សារុំ បន្ទាប់មកសមត្ថកិច្ចបន្តឃាត់ខ្លួនខ្លួនភ្លាមៗតែម្តង ។ ខ្លួនមិនបានដឹងរឿងអ្វីទាំងអស់ឈ្មោះ [redacted] សារុំ ហៅខ្លួនមកខ្លួនក៏មកជាមួយទៅដោយមិនបានដឹងថាឈ្មោះ [redacted] សារុំ ជួញដូរគ្រឿងញៀននោះទេ ។ សំណូមពរសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្លួនរួចផុតពីបទចោទប្រកាន់នេះផងព្រោះខ្លួនមិនបានដឹងរឿងអ្វីទាំងអស់ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាពិនិត្យ និងសម្រេចតាមច្បាប់ ។

-លោក [redacted] ប៊ុនធឿន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា កូនក្តីខ្លួនឈ្មោះ [redacted] សារុំ បានឆ្លើយសារភាពចំពោះមុខក្រុមប្រឹក្សារួចហើយថាខ្លួនបានយកថ្នាំញៀនឱ្យគេមែន សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើទោសដើម្បីបន្ធូរបន្ថយទោសដល់រូបគាត់ ។ នៅក្នុងនោះការដែលកូនក្តីខ្លួនប្តឹងមកឧទ្ធរណ៍ដោយសារតែការផ្តន្ទាទោសធ្ងន់ធ្ងរពេកគឺផ្តន្ទាទោស ២០ (ម្ភៃ)ឆ្នាំ និងពិន័យជាប្រាក់ ៨០.០០០.០០០ (ប៉ែតសិបលាន)រៀល ប៉ុន្តែបើយើងពិនិត្យទៅលើផ្លូវច្បាប់វិញតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឃើញថាមានកម្រិតទាបណាស់ទៅហើយ តែការដែលពិន័យជាប្រាក់នោះគឺច្រើន

ពេក អញ្ចឹងសូមឱ្យទម្លាក់អប្បបរមានៃការពិន័យជាប្រាក់ត្រឹម ៤០.០០០.០០០ (សែសិបលាន)រៀល បានហើយ និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើស្ថានភាពរបស់ជនជាប់ចោទនេះគឺថា មិនមានការចេះដឹង យល់ដឹងជ្រៅជ្រះទេ ហើយជីវភាពក៏មានការលំបាក ។ ដូច្នេះស្នើសុំក្រុមប្រឹក្សា បន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឈ្មោះ [redacted] សារុំ ផង ។ ចំពោះឈ្មោះ [redacted] សារ៉ាត វិញតាំងពីដើមមក គឺឆ្លើយមិនបានដឹងទេថាខ្លួនដឹកឈ្មោះ [redacted] សារុំ ដើម្បីមកជួញដូរគ្រឿងញៀនដើម្បីទិញលក់នឹងគឺមិន បានដឹងអ្វីទាំងអស់ រហូតដល់ពេលនេះក៏បានឆ្លើយថាខ្លួនមិនបានដឹងអ្វីទាំងអស់ ។ ដូច្នេះ ស្នើសុំក្រុម ប្រឹក្សាជំនុំជម្រះឱ្យជនជាប់ចោទឈ្មោះ [redacted] សារ៉ាត រួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សារុំ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ “ក” ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលា ដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេចបញ្ចប់ ធ្វើឡើងតាមកំណត់ច្បាប់ សាលា ឧទ្ធរណ៍បាត់ដំបង អាចលើកសំណុំរឿងនេះដើម្បីជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ “ក” ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់ សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេចបញ្ចប់ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង អាចលើកសំណុំរឿងនេះដើម្បីជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ ថ្មី នៃ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្ម ទណ្ឌ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-នាពេលសវនាការសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ ទូច សារុំ បានឆ្លើយបដិសេធថាខ្លួន មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តែខ្លួនទទួលស្គាល់ថាគេបានផ្ញើឥវ៉ាន់ឱ្យខ្លួនមិនដឹងថាជា



Scanned with CamScanner

គ្រឿងញៀនទេ ។ ប៉ុន្តែជនជាប់ចោទបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ថ្នាំញៀនជារបស់ខ្លួន ហើយថ្នាំញៀនយកឱ្យគេនោះមានតម្លៃ ១.៣០០០$ (មួយម៉ឺនបីពាន់)ដុល្លារអាមេរិក ដោយក្នុង ១គីឡូក្រាម ខ្លួនចំណេញ ៣០០០$ (បីពាន់)ដុល្លារអាមេរិក ។ ថ្នាំញៀនចំនួន ៥គីឡូក្រាម ដែលខ្លួនទិញក្នុង ១គីឡូ តម្លៃ ១.០០០០ (មួយម៉ឺន)ដុល្លារអាមេរិក ។ ខ្លួន និងក្មួយបានជិះម៉ូតូទៅជួបម្ចាស់ថ្នាំញៀន ដោយដាក់ការ៉ុងរួចខ្លួនជិះម៉ូតូមកលក់ថ្នាំញៀនឱ្យគេចំនួន ៥គីឡូក្រាម ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន និងក្មួយរួមជាមួយថ្នាំញៀន ៥គីឡូក្រាម ។ ចម្លើយឆ្លើយដោះសាររបស់ជនជាប់ចោទមិនមានភស្តុតាងណាមកបញ្ជាក់ឱ្យតុលាការជឿឡើយ ហើយជនជាប់ចោទក៏បានឆ្លើយថា នៅពេលឃាត់ខ្លួនពិតជាមានថ្នាំញៀនមែន ។ ម្យ៉ាងទៀតការឆ្លើយដោះសារនេះគ្មានចម្លើយឈ្មោះ ខូវ មកបញ្ជាក់ភាពស្អាតស្អំរបស់ជនជាប់ចោទឡើយ ។

៤-នាពេលសវនាការសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ [redacted]សារ៉ាត បានឆ្លើយថា ខ្លួនមិនបានដឹងថាជាគ្រឿងញៀនទេ ហើយឈ្មោះ [redacted] សារុំ ក៏មិនបានប្រាប់ដែរ ។ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សារ៉ាត បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច បានសារភាពថា ខ្លួនពិតជាបានជូនពូរបស់ខ្លួនឈ្មោះ [redacted] សារុំ ទៅលក់ថ្នាំញៀនចំនួន ៥គីឡូក្រាមមែន ហើយសមត្ថកិច្ចឃាត់ពួកខ្លួនពេលជិះម៉ូតូចូលក្រុងតាមមាត់ស្ទឹងសង្កែ ។ ដូច្នេះ ចម្លើយដោះសាររបស់ជនជាប់ចោទរូបនេះពុំមានភស្តុតាងមកបញ្ជាក់ឡើយ ជាចម្លើយដោះសារដើម្បីគេចវេសពីការទទួលខុសត្រូវប៉ុណ្ណោះ ។ ម្យ៉ាងនៅពេលសមត្ថកិច្ចចាប់ខ្លួនបានគឺជនជាប់ចោទរូបនេះ និងជនជាប់ចោទឈ្មោះ [redacted] សារុំ កំពុងដឹកគ្រឿងញៀនទៅឱ្យគេ ។ ដូច្នេះអ្នកទាំងពីរពិតជាបានសហការគ្នា និងបែងចែកផលប្រយោជន៍គ្នានៅពេលលក់ថ្នាំញៀនបានសម្រេច ។

៥-តាមលទ្ធផលនៃការធ្វើកោសលវិច័យសារធាតុញៀនដែលបានដកហូតចំនួន ៥០០០ ក្រាមនេះ គឺមានសារធាតុញៀនជាប្រភេទមេតំហ្វេតាមីនធាតុសុទ្ធស្មើនឹងចំនួន ៣៦៤២.១៥ ក្រាម ដែលកម្រិតនេះត្រូវផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៧ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដូច្នេះ សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted]សារុំ សាលាឧទ្ធរណ៍មិនអាចលើកយកមកធ្វើការពិចារណាទៀតទេ ព្រោះសាលាដំបូងបានផ្តល់ស្ថានសម្រាលទោសត្រឹមអប្បបរមានៃទោសរួចហើយ ចំពោះទោសដាក់ពន្ធនាគារ ហើយទោសពិន័យជាប្រាក់ក៏មានលក្ខណៈសមរម្យដែរ ។

៦-តំណាងមហាអយ្យការបានបានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា ពិនិត្យ និងសម្រេច ។ សេចក្តីសន្និដ្ឋាននេះក្រុមប្រឹក្សាជំនុំជម្រះនឹងលើកយកមកពិចារណា និងសម្រេចដូចមានក្នុងសំអាងហេតុនេះ ។

៧-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] សារុំ បានឆ្លើយសារភាពហើយនិងស្នើសុំបន្ធូរបន្ថយទោស ។ ចំពោះការសុំបន្ធូរបន្ថយទោសនេះពុំ



Scanned with CamScanner

មានមូលដ្ឋានដែលអាចឱ្យសភាព្រហ្មទណ្ឌលើកយកមកជាសំអាងឡើយ ។ ចំណែកឯសេចក្តីសន្និដ្ឋានសុំឱ្យជនជាប់ចោទឈ្មោះ [redacted] សារ៉ាត រួចខ្លួនពីបទចោទប្រកាន់ ដោយផ្អែកលើចម្លើយរបស់ជនជាប់ចោទនាពេលសវនាការសាលាឧទ្ធរណ៍នេះ មិនមានមូលហេតុ និងភស្តុតាងដែលអាចឱ្យក្រុមប្រឹក្សាលើកយកមកពិចារណាឡើយ ព្រោះនៅពេលដកហូតថ្នាំញៀនអ្នកទាំងពីរបានកំពុងតែជិះម៉ូតូជាមួយគ្នា ហើយចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត នៅសមត្ថកិច្ចស្របនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុំ ថាខ្លួនបានដឹងថា សមត្ថកិច្ចដកហូតថ្នាំញៀន ៥ គីឡូក្រាម ។

៧-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សារុំ ភេទប្រុស អាយុ៥៩ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ពីបទ៖ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យសោហី ស្ថិតនៅក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៧ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **សារ៉ាត** ភេទប្រុស អាយុ៣៥ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ពីបទ៖ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យសោហី ស្ថិតនៅក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩-រឿងក្តីនេះត្រូវបានសាលាដំបូងខេត្តបាត់ដំបងលើកយកមកសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពដោយមិនចាំបាច់លើកយកសំអាងហេតុដដែលមកបញ្ជាក់សារជាថ្មីទេ ។

១០-សាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ “ក”/១៣ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ ហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

**១**-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សារុំ និងពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៦៤ “ក” ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារុំ និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ។

រក្សាសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១១កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាដំបូងខេត្តបាត់ដំបង, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]